# ពន្លឺនៃព្រះគ្រីស្ទ

## និយមន័យនៃពន្លឺនៃព្រះគ្រីស្ទ

សូមអាន គោលលទ្ធិ និងសេចក្ដីសញ្ញា ៨៨:១២–១៣ ដោយរកមើលការពិពណ៌នានៃពន្លឺនៃព្រះគ្រីស្ទ ។

សូមអាននិយមន័យខាងក្រោមនៃពន្លឺនៃព្រះគ្រីស្ទ ៖

« [ ពន្លឺនៃព្រះគ្រីស្ទ ] « គឺជាកម្លាំង អំណាច ឬឥទ្ធិពលដ៏ទេវភាព ដែលមានមកពីព្រះតាមរយៈព្រះគ្រីស្ទ ហើយផ្ដល់ជីវិត និងពន្លឺដល់អ្វីៗទាំងអស់ ។ វាគឺជាច្បាប់ដែលគ្រប់យ៉ាងត្រូវគ្រប់គ្រងនៅស្ថានសួគ៌ និងនៅលើផែនដី ( គ&ស ៨៨:៦–១៣ ) ។ វាក៏ជួយមនុស្សឲ្យយល់ពីសេចក្ដីពិតនៃដំណឹងល្អ ហើយជួយដាក់ពួកគេទៅលើផ្លូវនៃដំណឹងល្អដែលនាំទៅរកសេចក្ដីសង្គ្រោះ » ។ ( សេចក្ដីណែនាំដល់បទគម្ពីរទាំងឡាយ « ពន្លឺ, ពន្លឺនៃព្រះគ្រីស្ទ » នៅលើគេហទំព័រ scriptures.ChurchofJesusChrist.org )

- តើអ្នកនឹងសង្ខេបអំពីអ្វីដែលអ្នកយល់ពីពន្លឺនៃព្រះគ្រីស្ទយ៉ាងដូចម្ដេច ?
- តើអ្នកគិតថាអ្នកត្រូវបានទទួលឥទ្ធិពលដោយផ្ទាល់ដោយពន្លឺនៃព្រះគ្រីស្ទយ៉ាងដូចម្ដេច ?

## ពន្លឺនៃព្រះគ្រីស្ទជាសតិសម្បជញ្ញៈរបស់យើង ។

ការបង្ហាញមួយនៃពន្លឺនៃព្រះគ្រីស្ទ គឺជាសតិសម្បជញ្ញៈរបស់យើង ។ សូមសរសេរនិយមន័យថា កុមារអង្គការបឋមសិក្សានឹងយល់អំពីអ្វីដែលអ្នកយល់អំពីសតិសម្បជញ្ញៈ ។

សូមអាននិយមន័យខាងក្រោម ហើយរកមើលអ្វីដែលអ្នកអាចបន្ថែមទៅនឹងនិយមន័យរបស់អ្នក ៖

« [ សតិសម្បជញ្ញៈគឺជា ] អារម្មណ៍ពីក្នុងខ្លួននៃការដឹងខុស និងត្រូវ ចេញមកពីពន្លឺនៃព្រះគ្រីស្ទនៅក្នុងមនុស្សទាំងអស់ ( ម៉ូរ៉ូណៃ ៧:១៦ ) ។ យើងកើតមកដោយមានសមត្ថភាពពីធម្មជាតិក្នុងការបែងចែករវាងខុស និងត្រូវ ដោយសារពន្លឺនៃព្រះគ្រីស្ទ ដែលត្រូវបានប្រទានដល់មនុស្សគ្រប់រូប ( គ&ស ៨៤:៤៦ ) ។ ញាណសតិនេះហៅថា សតិសម្បជញ្ញៈ ។ ការទទួលបានញាណសតិនេះធ្វើឲ្យយើងជាមនុស្សមានការទទួលខុសត្រូវ ។ ដូចជាញាណសតិផ្សេងទៀតដែរ សតិសម្បជញ្ញៈរបស់យើងអាចនឹងត្រូវស្លាប់ដោយសារអំពើបាប ឬការប្រើប្រាស់ខុស » ។ ( សេចក្ដីណែនាំដល់បទគម្ពីរទាំងឡាយ « បញ្ញាចិត្ត, សតិ, សតិសម្បជញ្ញៈ » នៅលើគេហទំព័រ scriptures.ChurchofJesusChrist.org )

សូមអាន គោលលទ្ធិ និងសេចក្ដីសញ្ញា ៨៤:៤៥–៤៦ និង ម៉ូរ៉ូណៃ ៧:១៦ ដោយរកមើលពាក្យ ឬឃ្លាដែលពិពណ៌នាអំពីរបៀបដែលពន្លឺនៃព្រះគ្រីស្ទដើរតួជាសតិសម្បជញ្ញៈរបស់យើង ។ សូមពិចារណាបង្កើតសេចក្ដីយោងឆ្លងសម្រាប់ខគម្ពីរទាំងពីរ ។

- តើឃ្លាមួយណាមកពីខគម្ពីរទាំងនេះ ដែលជួយអ្នកយល់ថាអ្វីជាសតិសម្បជញ្ញៈ ?
- តើអ្នកគិតថា ហេតុអ្វីព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទប្រទានសតិសម្បជញ្ញៈដល់អ្នក ?

តើការស្ដាប់ ឬព្រងើយកន្តើយនឹងសតិសម្បជញ្ញៈរបស់អ្នកអាចមានឥទ្ធិពលលើជម្រើសដែលអ្នកធ្វើ និងគោលដៅដ៏អស់កល្បជានិច្ចរបស់អ្នកដោយរបៀបណា ?

## ពន្លឺនៃព្រះគ្រីស្ទគឺនៅក្នុងមនុស្សគ្រប់រូប

សូមស្រមៃថាអ្នកត្រូវបានស្នើសុំឲ្យចែកចាយគំនិតខ្លីមួយនៅក្នុងសាលាថ្ងៃអាទិត្យអំពីរបៀបមើល និងប្រព្រឹត្តចំពោះមនុស្សទាំងអស់ឲ្យកាន់តែប្រសើរឡើង ជាពិសេសចំពោះមនុស្សដែលខុសពីអ្នក ។ អ្នកអាចប្រើធនធានដូចខាងក្រោម និងអ្វីផ្សេងទៀតដែលអ្នករកឃើញថាមានប្រយោជន៍ ។

គោលលទ្ធិ និងសេចក្ដីសញ្ញា ៨៨:១១

គោលលទ្ធិ និងសេចក្ដីសញ្ញា ៩៣:២

ប្រធាន ប៊យដ៍ ខេ ផាកកឺ ( ឆ្នាំ ១៩២៤–ឆ្នាំ ២០១៥ ) ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានបង្រៀន ៖



កាលណាយើងកាន់តែដឹងច្រើនអំពីពន្លឺនៃព្រះគ្រីស្ទច្រើនប៉ុនណា នោះយើងក៏នឹងកាន់តែយល់អំពីជីវិត និងកាន់តែមានសេចក្ដីស្រឡាញ់ជ្រាលជ្រៅចំពោះមនុស្សលោកទាំងអស់ច្រើនប៉ុណ្ណោះដែរ ។ យើងនឹងក្លាយជាគ្រូបង្រៀន និងជាអ្នកផ្សព្វផ្សាយសាសនា និងជាឪពុកម្ដាយដ៏ល្អប្រសើរ ហើយជាបុរស និងជាស្ត្រី និងជាកូនកាន់តែប្រសើរឡើង ។ យើងនឹងមានការគោរពកាន់តែជ្រាលជ្រៅចំពោះបងប្អូនប្រុសស្រីរបស់យើងក្នុងសាសនាចក្រ និងចំពោះអ្នកដែលមិនជឿ ។ . . .

ពន្លឺនៃព្រះគ្រីស្ទ មានលក្ខណៈទូលំទូលាយដូចជាពន្លឺព្រះអាទិត្យដែរ ។ ទីណាដែលមានជីវិតមនុស្សរស់នៅ ទីនោះមានព្រះវិញ្ញាណនៃព្រះគ្រីស្ទ ។ គ្រប់ព្រលឹងនៃភាវរស់ តែងមានវាជានិច្ច ។ . . .